សប្តាហ៍ទី 26

លោកមេទ័ពណាម៉ាន់

មេទ័ពណាម៉ាន់បានជាសះស្បើយ ដោយជឿ និងស្តាប់បង្គាប់ព្រះ!

រឿងក្នុងព្រះគម្ពីរ

មេទ័ពណាម៉ាន់ជាមេទ័ពដ៏ក្លាហានម្នាក់ ប៉ុន្តែគាត់មានជំងឺឃ្លង់យ៉ាងធ្ងន់ធ្ងរ។
អេលីសេ ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ បានប្រាប់គាត់ថា៖ «ចូរទៅជ្រមុជខ្លួនក្នុងទន្លេយ័រដាន់ប្រាំពីរដងទៅ»។
មេទ័ពណាម៉ាន់បានធ្វើតាមពាក្យដែលបានប្រាប់ ដោយចុះជ្រមុជខ្លួនក្នុងទន្លេយ័រដាន់ប្រាំពីរដង។
នៅពេលនោះ ជំងឺឃ្លង់របស់គាត់បានជាសះស្បើយទាំងស្រុង!
មេទ័ពណាម៉ាន់បានជឿថា ព្រះជាម្ចាស់ពិតជាព្រះដ៏មានព្រះចេស្តា។
យើងក៏ត្រូវជឿ និងស្តាប់បង្គាប់ព្រះជាម្ចាស់ដែរ នោះព្រះជាម្ចាស់នឹងជួយយើង!

សមិទ្ធផលសម្រេច



ប្រើក្រដាសជូតមាត់ (ឬក្រដាសអនាម័យ) ដើម្បីបង្កើតជារូបទន្លេយ័រដាន់ ហើយតុបតែងរូបមេទ័ពណាម៉ាន់ រួចបិទ ដើម្បីបង្កើតជាស្នាដៃដ៏ស្រស់ស្អាត!

វត្ថុបំណង

- ស្គាល់រឿងមេទ័ពណាម៉ាន់
- រៀនអំពីចិត្តដែលជឿ និងស្តាប់បង្គាប់ព្រះជាម្ចាស់
- ប្រើក្រដាសផ្ទះបាយ (ឬក្រដាសអនាម័យ) ធ្វើរូបទន្លេយ័រដាន់
- បណ្តុះដួងចិត្តដឹងគុណចំពោះព្រះជាម្ចាស់តាមរយៈស្នាដៃដែលបានធ្វើរួច។

សម្ភារៈ


ក្រដាសផ្ទះបាយ (ឬក្រដាសអនាម័យ)


ក្រដាសរឹង (ឬចានក្រដាស)


ថ្នាំពណ៌ខៀវ


ប្រដាប់បន្តក់ថ្នាំពណ៌ /ជក់


កន្ត្រៃ


ការ


ខ្មៅដៃពណ៌ /ហ្វឺត


ក្រដាសកិច្ចការរូបមេទ័ពណាម៉ាន់

របៀបធ្វើ

1 ការហែកក្រដាសជាបំណែកតូចៗ



យកក្រដាសជូតមាត់ ឬក្រដាសអនាម័យ ហែកជាបំណែកតូចៗតាមចំណង់ចំណូលចិត្ត។

2 ការជាត់ពណ៌



លាយថ្នាំពណ៌ ពណ៌ខៀវជាមួយទឹកបន្តិច។ ប្រើឧបករណ៍បន្តក់ថ្នាំពណ៌ ឬជក់ ដើម្បីលាបពណ៌លើបំណែកក្រដាសដែលបានហែក។

3 ការបង្កើតទឹក



លាបកាវលើផ្នែកខាងក្រោមនៃចានក្រដាស។ យកបំណែកក្រដាសដែលបានលាបពណ៌ខៀវ មកបិទត្រួតលើគ្នា ដើម្បីបង្កើតជាទឹកទន្លេយ័រដាន់។

4 ការតុបតែងទេសភាពជុំវិញ



គូររូបស្មៅ ថ្ម និងពពកជាដើម រួចជាត់ពណ៌។ បន្ទាប់មក កាត់ ហើយបិទតុបតែងជុំវិញទន្លេយ័រដាន់។

5 ការតុបតែងមេទ័ពណាម៉ាន់



ជាត់ពណ៌រូបមេទ័ពណាម៉ាន់។ កាត់រូបនោះ រួចបិទនៅចំកណ្តាលទន្លេយ័រដាន់។

6 រួចរាល់!



មើលសមិទ្ធផលដែលរួចរាល់ ហើយអរគុណដល់ព្រះជាម្ចាស់!

ការពង្រីកសកម្មភាព

- ឱ្យកុមារលេងជាមួយគ្នាលើទន្លេយ័រដាន់ដែលបានធ្វើដោយយករូបមេទ័ពណាម៉ាន់មកដាក់លើទន្លេ។
- ប្រើស្លឹកគំរាលេខ ៧ ដើម្បីរាប់ចំនួនដងដែលមេទ័ពណាម៉ាន់បានជ្រមុជខ្លួនក្នុងទឹក។
- ឱ្យកុមារប្រើម្រាមដៃតាមចំនួនប្រាំពីរ ហើយនិយាយថា «ខ្ញុំហាត់ស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់»។



Tip សម្រាប់គ្រូ

- ពេលក្រដាសសើមខ្លាំងពេក វាអាចនឹងងាយហែក ដូច្នេះសូមបង្ហាញគម្រូដល់កុមារពីរបៀបហែក និងបិទវាដោយថ្នមៗ។
- ណែនាំកុមារឱ្យបិទបំណែកក្រដាសត្រួតលើគ្នាពីក្រោមឡើងលើ ដើម្បីឱ្យរូបទឹកមើលទៅមានលក្ខណៈធម្មជាតិ។
- បើប្រើណ៍ខៀវប្រដេញ ចាប់ពីពណ៌ស្រាលទៅចាស់ កាន់តែស្អាត។
- លើកទឹកចិត្តកុមារឱ្យតុបតែងតាមគំនិតច្នៃប្រឌិតរបស់ខ្លួន ហើយពិភាក្សាអំពីសារៈសំខាន់នៃការជឿ និងការស្តាប់បង្គាប់។

